00824086

E190/2/corr-1

ព្រះរាជាណាចក្រកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E190/2 | 00813600-00813602 | 16 July 2012 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| ដោយសារតែមិនបានដាក់ឯកសារលេខរៀង ១៥ ដែលមាននៅក្នុងឯកសារ E109/1.1 |

| សេចក្ដីលម្អិតនៃការកែតម្រូវ៖ |
|---|
| កថាខណ្ឌ ៧៖ បន្ថែមឃ្លា លេខ ១៥ និងប្ដូរលេខ ១៦ ទៅ ១៧ |
| កថាខណ្ឌ ១០៖ ប្ដូរ លេខ ១៨ ទៅ ១៩ |
| កថាខណ្ឌ ១១៖ ប្ដូរ លេខ ១៨ ទៅ ១៩ |
| កថាខណ្ឌ ១២៖ ប្ដូរ លេខ ១៩ ទៅ ១៨ |

ភាគីស្នើសុំ៖ អង្គជំនុំជម្រះសាលាដំបូង — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 07 / 2012
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

00824087

E190/2/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

កាលបរិច្ឆេទ: ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

## សេចក្តីសម្រេចស្តីពីការដាក់ឯកសារថ្មីចូលទៅក្នុងសំណុំរឿង

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS

គង់ សំអុន
Jaques VERGÈS
Arthur VERCKEN
Anta GUISSÉ

00824088

E190/2/Corr-1

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាដែលបាន ចេញដោយអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1]។

**បានឃើញ** សេចក្តីសម្រេចរបស់ខ្លួនទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (ឯកសារ E190) ("សេចក្តីសម្រេច") ដែលបានបង្គាប់ឲ្យភាគីដាក់ចូលទៅក្នុងប្រព័ន្ធផ្ទុក ឯកសាររួម ឬឲ្យភាគីពិនិត្យមើលបាន ត្រឹមថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ នូវឯកសារថ្មីចំនួន ៣៧ ដែលត្រូវ បានកំណត់អត្តសញ្ញាណក្នុងកថាខណ្ឌ ២៨ នៃសេចក្តីសម្រេចនេះ។

**បានឃើញ** សេចក្តីសម្រេចនេះត្រូវបានដាក់ជាភាសាបារាំង កាលពីថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ ហើយ ភាគីពុំមានលទ្ធភាពដាក់ឯកសារនានាចូលទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម នៅរវាងថ្ងៃទី ១២ និងថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២ ដោយសារថ្ងៃទាំងនេះគឺជាថ្ងៃឈប់សម្រាករបស់បុគ្គលិក អ.វ.ត.ក។

**បានឃើញ** មេធាវីការពារជនជាប់ចោទ អៀង សារី បានដាក់ឯកសារថ្មីចំនួនមួយ (ឯកសារលេខ ៨ នៅក្នុង ឯកសារ E109/6.2) ចូលទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២។

**បានឃើញ** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ (ឯកសារ E190/1) ដែល បានបញ្ជាក់អំពីទីតាំងនៃឯកសារថ្មីចំនួន ២ (ឯកសារលេខ ២៣៣ ក្នុងឯកសារ E109/4.1 និងឯកសារលេខ ១៧ ក្នុងឯកសារ E109/4.5)។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្ត ថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។

**បានឃើញ** ឯកសារថ្មីចំនួន ១៧៦ នៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមដែលបានដាក់ដោយមេធាវីការពារជនជាប់ចោទ ខៀវ សំផន កាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ (ឯកសារលេខ ១, លេខ ៧, លេខ ១១, លេខ ១៤, លេខ ១៥, លេខ ១៦, លេខ ១៧, លេខ ១៨, លេខ ១៩, លេខ ២០, លេខ ២១, លេខ ២២, លេខ ២៣, លេខ ២៥, លេខ ២៦, លេខ ២៧ និងលេខ ២៨ ក្នុងឯកសារ E109/1.1)។

**បានឃើញ** ឯកសារលេខរៀង ២៣៣ ក្នុងឯកសារ E109/4.1 ស្ថិតនៅក្នុងសំណុំរឿងរួចហើយ ជាឯកសារលេខ E109/2.3 R បន្ទាប់ពីមានសេចក្តីសម្រេចនេះ។

**ពិចារណា** ថាមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានដាក់ឯកសាររបស់ខ្លួនទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមឆាប់ៗតាមការជាក់ស្តែង បន្ទាប់ពីមានសេចក្តីសម្រេចជាភាសាបារាំងបានដាក់ចូលទៅក្នុងសំណុំរឿង។

**ពិចារណា** ថាឯកសារថ្មីចំនួន ១៩៨ ដែលមេធាវីការពារជនជាប់ចោទ អៀង សារី សហព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានផ្តល់គឺ *តាមការពិនិត្យបឋម* នាំទៅដល់ការបញ្ជាក់ការពិតក្នុងសំណុំរឿងលេខ០០២។

**សម្រេចដាក់** នូវឯកសារថ្មីចំនួន ១៩៨ ដែលមានរាយនាមនៅក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយសេចក្តីសម្រេចនេះ ទៅក្នុងសំណុំរឿង។

**ស្នើសុំ** ភាគីថា អង្គជំនុំជម្រះអាចចាត់ទុកការប៉ុនប៉ងណាមួយ ដើម្បីសំអាងទៅលើឯកសារថ្មីមួយចំនួន នៃឯកសារ ១៨៩ ដែលនៅសេសសល់ ដូចដែលត្រូវបានបង្ហាញអត្តសញ្ញាណ នៅក្នុងកថាខណ្ឌ២៨ នៃសេចក្តីសម្រេចនេះ ថាជាសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**